អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ១៧ ខែ កុម្ភៈឆ្នាំ២០១០

# សេចក្តីប្រកាសព័ត៌មាន

## ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងបង្កើតសាលាក្តី "ឌីជីថល" (Virtual Tribunal)

នៅថ្ងៃនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក) បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយវិទ្យាស្ថានហ៊ូវើ (Hoover Institution) នៃសាកលវិទ្យាល័យស្តែនហ្វត (Stanford University) និងមជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាមនៃសាកលវិទ្យាល័យកាលីហ្វ័រនី ប៊ឺរឃ្លី (University of California, Berkeley) ដើម្បីបង្កើត ***គម្រោងមរតកសាលាក្តីឌីជីថល នៃអវតក*** (ECCC Virtual Tribunal Legacy Project)។

សាលាក្តីឌីជីថលនេះនឹងក្លាយជាចំណុចចាប់ផ្តើមដំបូងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងការផ្តល់ឲ្យសាធារណៈជនទូទៅនូវឯកសារផ្សេងៗ ជាលក្ខណៈឌីជីថលទាក់ទងទៅនឹងដំណើរការកាត់ក្តី ដូចជា៖ សេចក្តីសម្រេច របស់តុលាការ ការដាក់ឯកសារ ប្រតិចារឹក និង វីដេអូ ដែលបង្ហាញអំពីកិច្ចនីតិវិធីទាំងឡាយ។ សាលាក្តីឌីជីថលនៃអ.វ.ត.ក នឹងបង្កើតបណ្តាញភ្ជាប់ទៅរាល់ឯកសារទាំងអស់ ព្រមទាំងបញ្ចូលគ្នា ដោយអមជាមួយសេចក្តីអត្ថាធិប្បាយរបស់អ្នកជំនាញ ការណែនាំអប់រំ ការពន្យល់ បទសម្ភាសន៍ និងឯកសារព័ត៌មានជាច្រើនទម្រង់ផ្សេងៗទៀត។

សាធារណៈជនទូទៅនឹងអាចប្រើប្រាស់សាលាក្តីឌីជីថលអ.វ.ត.កនេះបាន ទាំងក្នុងអំឡុងពេលដំណើរការរបស់តុលាការនិងពេលបញ្ចប់តុលាការ។ សាលាក្តីឌីជីថលនៃអ.វ.ត.កនឹងបង្កើតឡើងនៅតាមសាលារៀននានា បណ្តាសាកលវិទ្យាល័យ មហាវិទ្យាល័យច្បាប់ និងនៅតាមកន្លែងដទៃទៀត ក្នុងគោលបំណងដើម្បីផ្តល់ភាពងាយស្រួលដល់ប្រជាជននៅ ក្នុងប្រទេសកម្ពុជាអាចចូលសិក្សាស្រាវជ្រាវបាន។

ចំពោះព័ត៌មានបន្ថែម សូមទាក់ទង៖

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

លោក **រាជ សម្បត្តិ**
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855(0) 12 488 156
ទូរសារលេខ +855(0)23 219 841
សារអេឡិចត្រូនិក reach.sambath@eccc.gov.kh

លោក **ឌីម សុវណ្ណារុំ**
មន្ត្រីទទួលបន្ទុកការងារព័ត៌មាន
ទូរស័ព្ទចល័តលេខ +855(0) 12 488 094
ទូរសារលេខ +855(0)23 219 841
សារអេឡិចត្រូនិក dim.sovannarom@eccc.gov.kh

លោក **ឡាស អូលសិន**
មន្ត្រីច្បាប់ទទួលផ្នែកទំនាក់ទំនង
ទូរស័ព្ទចល័តលេខ +855(0) 12 488 023
ទូរសារលេខ +855(0)23 219 841 លេខបន្ត 6169
សារអេឡិចត្រូនិច olsenl@un.org

លោកស្រី**យូកូមេដា**
មន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855(0) 12 488 319
ទូរសារលេខ +855(0)23 219 841 លេខបន្ត 6139
សារអេឡិចត្រូនិក maeday@un.org